# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៤ សសរ

## សេចក្តីសំរេច
### ស្តីពី
### ការបង្កើតក្រុមការងារចាត់ចែងការចេញដំណើរពីកម្ពុជា នៃជនជាតិព្រៃភ្នំវៀតណាម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីអន្តោប្រវេសន៍
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតក្រុមការងារសំរាប់ចាត់ចែងការចេញដំណើរពីកម្ពុជា នៃជនជាតិព្រៃភ្នំវៀត-ណាម ដែលកំពុងស្នាក់នៅបណ្តោះអាសន្នក្នុងខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ដូចមានសមាសភាពខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម នាយឧត្តមសេនីយ៍ ហុក ឡងឌី | អគ្គស្នងការនគរបាលជាតិ | ជាប្រធាន |
| ២- ឯកឧត្តម ឡុង វិសាលោ | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម សក់ សេដ្ឋា | អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៤- ឯកឧត្តម ខាំ ខឿន | អភិបាល ខេត្តរតនគិរី | សមាជិក |
| ៥- ឯកឧត្តម ឆោ សឿន | អភិបាល ខេត្តមណ្ឌលគិរី | សមាជិក |

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

- ទំនាក់ទំនងជាមួយតំណាងភាគីអាមេរិក និងតំណាងUNHCR ដើម្បីរៀបចំស្រង់ជាបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តទៅរស់នៅសហរដ្ឋអាមេរិក ។
- ទំនាក់ទំនងជាមួយតំណាងភាគីវៀតណាម និងតំណាងUNHCR ដើម្បីរៀបចំស្រង់ជាបញ្ជីឈ្មោះអ្នកស្ម័គ្រចិត្តត្រឡប់ទៅរស់នៅវៀតណាមវិញ ។
- ទំនាក់ទំនងជាមួយតំណាងUNHCR ដើម្បីអោយអង្គការនេះជួយសំរួលជាមួយភាគីអាមេរិក ឬប្រទេសទីពណាផ្សេង អោយយល់ព្រមទទួលយកអ្នកនៅសេសសល់ អោយអស់ពីកម្ពុជា ។
- ចាត់ចែងធ្វើបែបបទ លិខិតស្នាមផ្សេងៗ ពាក់ព័ន្ធដល់ការធ្វើដំណើរចេញពីកម្ពុជារបស់ជនជាតិព្រៃភ្នំវៀតណាមទាំងអស់ ។
- សហការជាមួយតំណាងUNHCR ដើម្បីគិតគូរដោះស្រាយមធ្យោបាយដឹកជញ្ជូន ស្បៀងអាហារ និងកន្លែងស្នាក់នៅបណ្តោះអាសន្នរយៈពេលខ្លី មុននឹងចេញដំណើរទៅសហរដ្ឋអាមេរិក ឬទៅប្រទេសទីព តាមយន្តហោះ ។

**ប្រការ ៣ :** - ក្រុមការងារនេះមានសិទ្ធិចាត់តាំងក្រុមជំនួយការតាមការចាំបាច់ ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

- ក្រុមការងារត្រូវរាយការណ៍ជាប្រចាំពីសកម្មភាពការងាររបស់ខ្លួន ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ។ ក្នុងករណីមានបញ្ហាស្មុគស្មាញមិនអាចដោះស្រាយបាន ត្រូវសុំយោបល់មកថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ភ្នំពេញ,ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋាន រដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី*
- *ក្រសួងមហាផ្ទៃ*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *គ្រប់សាមីជន*
- *ឯកសារ* ✓